# សាររបស់សម្តេច ជា ស៊ីម
# ប្រធានគណបក្សប្រជាជនកម្ពុជាក្នុងឱកាសរំលឹកខួបអនុស្សាវរីយ៍
# លើកទី២០នៃថ្ងៃបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា
# ( ០២-១២-១៩៧៨ - ០២-១២-១៩៩៨ )

**********

សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរគណៈ និង ព្រះថេរានុថេរគ្រប់ព្រះអង្គ ជាទីសក្ការៈ បងប្អូនរួមជាតិ ជាទីគោរពស្នេហាដ៏ខ្ពង់ខ្ពស់បំផុត

ថ្ងៃនេះជាថ្ងៃគំរប់ខួបអនុស្សាវរីយ៍លើកទី២០ នៃការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយដ៏សំខាន់ ជាប់ទាក់ទងនឹងអាយុជីវិតរបស់ប្រជាជាតិទាំងមូល និង ការគង់វង្សរីកចំរើនរបស់មាតុភូមិកម្ពុជា ។ ទោះបីរយៈពេល២០ឆ្នាំបានកន្លងផុតទៅពិតមែន ប៉ុន្តែអត្ថន័យជាប្រវត្តិសាស្ត្រនៃព្រឹត្តិការណ៍នេះ នៅតែស្ថិតស្ថេរជានិច្ចក្នុងដួងចិត្តនៃប្រជារាស្ត្រគ្រប់ៗរូប ។

យើងទាំងអស់គ្នាកំពុងរំលឹកខួបអនុស្សាវរីយ៍នេះ ក្នុងស្មារតីគោរពដឹងគុណដ៏ជ្រាលជ្រៅបំផុត ចំពោះកម្មាភិបាល យុទ្ធជន ប្រជាជន ព្រមទាំងមិត្តភក្តិជិតឆ្ងាយ ដែលបានធ្វើពលិកម្មដ៏ធំធេង និង បានរួមវិភាគទានដ៏ថ្លៃថ្លាបំផុត ដើម្បីសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍ និង ការចាប់ផ្តើមឡើងវិញរបស់កម្ពុជាលើមាគ៌ានៃការកសាងជាតិ ។

យើងបានចងចាំជានិច្ចថា មាតុភូមិយើងបានទទួលរងនូវមហាវិនាសកម្មដោយសង្គ្រាមដ៏អយុត្តិធម៌ រយៈពេលប្រាំឆ្នាំ ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ហើយបន្ទាប់មកបានបន្តធ្លាក់ចូលក្នុងគ្រោះមហន្តរាយនៃរបបប្រល័យពូជសាសន៍ប៉ុលពត១៩៧៥-១៩៧៩ ដែលពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្រ ។ ជន្ទះនយោបាយប្រកបដោយមហិច្ឆតារបស់ពួកមេដឹកនាំនៃរបបប្រល័យពូជសាសន៍ ដែលក្បត់ទាំងស្រុងនឹងផលប្រយោជន៍ជាតិ បានបង្កើតឡើងនូវមហាសោកនាដកម្ម និង ផលវិបាកដ៏ធំធេងចំពោះជាតិមិនអាចពណ៌នាបានឡើយ ។ នេះជាប្រវត្តិនៃការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុត ចំពោះកម្ពុជា និងចំពោះមនុស្សជាតិទាំងមូល ។

គឺក្នុងកាលៈទេសៈដ៏ធ្ងន់ធ្ងរបំផុតនេះហើយ ដែលរណសិរ្សសាមគ្គីសង្គ្រោះជាតិ បានបដិសន្ធិឡើងនាថ្ងៃ២ធ្នូឆ្នាំ១៩៧៨នៅស្រុកស្នួលខេត្តក្រចេះ ដើម្បីបំផុសនិងដឹកនាំប្រជាជនអោយក្រោកឈរឡើងធ្វើការតស៊ូរំដោះខ្លួន។ រណសិរ្សបានប្រកាសចេញនូវគោលនយោបាយ១១ "ខ" ហើយបានប្រមូលផ្តុំកំលាំងទូទាំងប្រទេស ដោយមានការជួយឧបត្ថម្ភយ៉ាងធំធេងពីរដ្ឋនិងប្រជាជនវៀតណាម ព្រមទាំងមិត្តភក្តិជិតឆ្ងាយ ដើម្បីសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍ រហូតសំរេចបានជ័យជំនះជាប្រវត្តិសាស្ត្រដ៏ត្រចះត្រចង់នៅថ្ងៃ៧មករាឆ្នាំ១៩៧៩ ។ ផ្តើមពីជ័យជំនះនេះ កម្ពុជាបានរស់ឡើងវិញ ហើយបានបើកឡើងនូវទំព័រថ្មីនៃប្រវត្តិសាស្ត្រកសាងទឹកដីរបស់ខ្លួន ។

ក្រោយថ្ងៃ៧មករា រដ្ឋអំណាចប្រជាជនបានបដិសន្ធិឡើង ក្នុងស្ថានភាពបាតដៃទទេ ខ្វះសព្វខ្វះគ្រប់ ហើយត្រូវប្រឈមមុខដោះស្រាយផលវិបាកលើគ្រប់វិស័យយ៉ាងច្រើនឥតគណនា ។ រណសិរ្សសាមគ្គីសង្គ្រោះជាតិ ដែលបន្ទាប់មកបានប្តូរឈ្មោះជារណសិរ្សសាមគ្គីកសាងមាតុភូមិ បានរួមសហការជិតស្និទ្ធជាមួយរដ្ឋអំណាច ខិតខំពង្រីកចលនាស្នេហាជាតិរបស់ប្រជាជន ដើម្បីទប់ស្កាត់ការប៉ុនប៉ងវិលត្រឡប់មកវិញ នៃរបបប្រល័យពូជសាសន៍ ស្តារវិស័យសេដ្ឋកិច្ច សង្គមកិច្ច អោយមានដំណើរការឡើងវិញនិងអភិវឌ្ឍន៍ជាជំហានៗ និង ជំរុញការអនុវត្តន៍នយោបាយបង្រួបបង្រួមផ្សះផ្សារជាតិ រហូតបានសំរេចកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសថ្ងៃទី២៣តុលាឆ្នាំ ១៩៩១ ដែលបានពង្រឹងមូលដ្ឋានគ្រឹះនៃសន្តិភាព ឯកភាពជាតិ លទ្ធិប្រជាធិបតេយ្យសេរី និង ការអភិវឌ្ឍន៍ ហើយបានធានានូវសិទ្ធិនិងអធិបតេយ្យដ៏ពេញលេញរបស់កម្ពុជា ។

ជនរួមជាតិជាទីគោរពស្នេហា យើងបានយល់ច្បាស់ថាអ្វីៗដែលយើងមាននៅថ្ងៃនេះ ហើយនឹងមាននៅអនាគតទៀតនោះ ផ្សារភ្ជាប់មិនអាចផ្តាច់ចេញពីស្មារតី២ធ្នូ និងស្មារតី៧មករាបានឡើយ ។ ហេតុនេះការប៉ុនប៉ងណាមួយដើម្បីលុបបំបាត់ ឬ បំភ្លេចចោលទិវាប្រវត្តិសាស្ត្រទាំង២នេះ គឺជាទង្វើផ្ទុយនឹងសច្ចធម៌ ដែលមិនអាចទទួលនូវការគាំទ្រពីប្រជាជនបានឡើយ ។

៥ឆ្នាំកន្លងមកនេះ ព្រះរាជាណាចក្រកម្ពុជាយើង បានសំរេចសមិទ្ធផលយ៉ាងច្រើនទាំងក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង ការបរទេស ។ ថ្វីបើការរីកចំរើនទាំងនោះមិនទាន់បានឆ្លើយតបទាំងស្រុងតាមសំណូមពររបស់ប្រជាជន ប៉ុន្តែវាបានបង្កើនថែមទៀតនូវបុព្វបទនិងលក្ខណសម្បត្តិចាំបាច់សំរាប់ការអភិវឌ្ឍន៍ដ៏ឆាប់រហ័សនាពេលអនាគត ។ លទ្ធផលយ៉ាងល្អប្រសើរនៃការបោះឆ្នោតថ្ងៃទី២៦កក្កដាឆ្នាំ១៩៩៨ ដែលបានប្រកបដោយលក្ខណៈសេរី យុត្តិធម៌ និង អហិង្សា គឺជាសមិទ្ធផលដ៏ថ្លៃថ្លាណាស់នៃដំណើរការលទ្ធិប្រជាធិបតេយ្យសេរី និង បានបង្ហាញច្បាស់នូវអ្វីៗដែលប្រជាពលរដ្ឋចង់បាន ។ ក្នុងដំណើរឈានទៅមុខ យើងពុំមែនជួបតែភាពអនុគ្រោះនោះទេ ការពិតយើងបានឆ្លងកាត់ឧបសគ្គនិងការលំបាកស្មុគស្មាញច្រើនណាស់ ជាពិសេសក្នុងការរក្សាស្ថិរភាពនយោបាយ និង សង្គម ប៉ុន្តែដោយឈរលើស្មារតីស្រឡាញ់សន្តិភាព ការបង្រួបបង្រួមជាតិ និង ការគោរពច្បាប់ ក្រោមព្រះរាជកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទនរោត្តមសីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈ យើងបានដោះស្រាយរួចនូវឧបសគ្គទាំងនោះ ។

ការសំរេចនូវសេចក្តីប្រកាសរួមអំពីគោលការណ៍សហប្រតិបត្តិការ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច ក្នុងកិច្ចប្រជុំកំពូលក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅប្រាសាទខេមរិន្ទព្រះបរមរាជវាំងថ្ងៃទី១២_១៣ខែវិច្ឆិកាឆ្នាំ១៩៩៨ កន្លងមកនេះ បានទំលាយភាពទាល់ច្រកមុននេះ ដែលធ្វើអោយគាំងដល់ដំណើរការនៃរដ្ឋសភាអាណត្តិទី២ និង ការរៀបចំរាជរដ្ឋាភិបាលថ្មី ។ សេចក្តីប្រកាសរួមនេះ បានបង្ហាញច្បាស់នូវការគោរពចំពោះបំណងប្រាថ្នារបស់ប្រជារាស្ត្រជាម្ចាស់ឆ្នោត ដែលប្រាថ្នាចង់បានរាជរដ្ឋាភិបាលមួយមានស្ថិរភាព តម្លាភាព និង ប្រសិទ្ធភាព ដែលជាតំណាងនូវឆន្ទៈនយោបាយរបស់ប្រជារាស្ត្រ

ភាគច្រើនលើសលប់ក្នុងសង្គមជាតិ ។ ផ្អែកលើសេចក្តីប្រកាសរួមនេះ គណបក្សទាំងពីរបានបំពេញបន្ថែមនូវរាល់លក្ខខណ្ឌ ដើម្បីធានាដល់ដំណើរការនៃរាល់ស្ថាប័នកំពូលរបស់រដ្ឋ ។ រដ្ឋសភាបានចាប់ផ្តើមដំណើរការជាប្រក្រតី ដើម្បីរ៉ាប់រងនូវភារកិច្ចយ៉ាងច្រើនដែលប្រជារាស្ត្រប្រគល់អោយ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនាប្រទេសជាតិ ។ រាជរដ្ឋាភិបាលថ្មី ត្រូវបានបង្កើតឡើងកាលពីថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ១៩៩៨ ដោយផ្អែកលើមូលដ្ឋាននៃលទ្ធផលបោះឆ្នោត ការផ្សះផ្សារជាតិ និងមូលដ្ឋានច្បាប់ ហើយបានឆ្លុះបញ្ចាំងពិតប្រាកដនូវឆន្ទៈ និង ផលប្រយោជន៏របស់ប្រជារាស្ត្រយើងគ្រប់មជ្ឈដ្ឋាន ។ ព្រមជាមួយនេះ ការត្រៀមរៀបចំដើម្បីបង្កើតស្ថាប័នព្រឹទ្ធសភា ក៏កំពុងមានការចំរើនទៅមុខ ដែលនឹងអាចសំរេចបានក្នុងរយះពេលដ៏ឆាប់នេះ ។

ភាពស្រអាប់នៃទិដ្ឋភាពនយោបាយក្រោយពេលបោះឆ្នោត ដែលបានសង្កត់ទំងន់លើចិត្តសាស្ត្រប្រជារាស្ត្រយើង ត្រូវបានបញ្ចប់ ហើយឥឡូវនេះយើងកំពុងស្ថិតនៅចំពោះមុខភារកិច្ចយ៉ាងច្រើន ដែលត្រូវបំពេញលើមាគ៌ាឆ្ពោះទៅរកអនាគតប្រកបដោយក្តីសង្ឃឹម គឺសន្តិភាព និង ការកាត់បន្ថយភាពក្រីក្រ ។

មេរៀនពិសោធន៏ដ៏មានតំលៃ ដែលយើងអាចដកចេញបានពីសភាពការណ៏ថ្មីៗនេះ គឺមេរៀនអំពីការអនុវត្តន៏ឆន្ទៈប្រជារាស្ត្រតាមរយះការបោះឆ្នោត អំពីសមត្ថភាព និង ភាពក្លាហានក្នុងការដោះស្រាយបញ្ហាជាតិយើង ដោយខ្លួនយើងផ្ទាល់ នេះជាខ្លឹមសារមួយសំខាន់ណាស់នៃការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ លើកស្ទួយកិត្តិយស និង អធិបតេយ្យជាតិយើង ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ប្រជារាស្ត្រកម្ពុជាសូមសំដែងគារវភក្តីភាពដ៏ជ្រាលជ្រៅបំផុត ថ្វាយព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចព្រះរាជអគ្គមហេសី ជាទីសក្ការះ ដែលបានបូជាព្រះកាយពល និងព្រះបញ្ញាញាណ ជំនះគ្រប់ឧបសគ្គ ដើម្បីនាំមកនូវសុខសន្តិភាព ការផ្សះផ្សារជាតិ ភាពចំរុងចំរើន និង កិត្តិយសដល់មាតុភូមិនិងប្រជារាស្ត្រ ។ សូមគុណបុណ្យព្រះរតនត្រ័យវត្ថុស័ក្តិសិទ្ធិក្នុងលោក ព្រមទាំងព្រះវិញ្ញាណក្ខ័ន្ធនៃអតីតព្រះមហាក្សត្រខ្មែរ ជួយបីបាច់ថែរក្សាព្រះករុណាជាអម្ចាស់និងសម្តេចព្រះរាជអគ្គមហេសី សូមមានព្រះជន្មាយុយឺនយូរ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់របស់ប្រជារាស្ត្រ ជាកូន ជាចៅ ចៅទួត ជារៀងរហូត ។

សូមសំដែងកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះសហគមន៏អន្តរជាតិ ប្រទេសជាមិត្តជិតឆ្ងាយ ដែលបានផ្តល់វិភាគទានដ៏ថ្លៃថ្លា ក្នុងដំណើរការសន្តិភាព ការផ្សះផ្សារជាតិ លទ្ធិប្រជាធិបតេយ្យ និង ការអភិវឌ្ឍន៏នៅកម្ពុជា ។

ដោយចងចាំជានិច្ចនូវស្មារតី២ធ្នូនិងស្មារតី៧មករាដ៏រុងរឿង គណបក្សប្រជាជនកម្ពុជានិងរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា នឹងបន្តខិតខំធ្វើអ្វីៗទាំងអស់ស្របតាមឆន្ទៈនិងជំនឿទុកចិត្តរបស់ប្រជាជន រួមជាមួយរាល់កំលាំងស្នេហាជាតិ ដើម្បីរក្សាសន្តិភាព ស្ថិរភាព និងឯកភាពជាតិ ដែលជាកត្តាមូលដ្ឋានដើម្បីធានាដល់ការស្តារនិងកសាងព្រះរាជាណាចក្រកម្ពុជាយើង អោយបានរីកចំរើនឆាប់រហ័ស ។ ក្នុងទិសដៅនេះ គណបក្ស

ប្រជាជនកម្ពុជានឹងធ្វើសហប្រតិបត្តិយ៉ាងជិតស្និទ្ធិបំផុត ជាមួយគណបក្សហ៊្វុនស៊ិនប៉ិចផ្អែកតាមខ្លឹមសារនៃពិធីសារនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងគណបក្សទាំង២ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ។ មានតែការយោគយល់គ្នា ជឿទុកចិត្តគ្នា ហើយរួបរួមគ្នាក្រោមរដ្ឋធម្មនុញ្ញ និងអនុវត្តនូវកម្មវិធីនយោបាយរួមមួយ ដោយបំភ្លេចនូវអតីតកាលដ៏ជូរចត់នៃជម្លោះផ្ទៃក្នុងនោះទេ ទើបយើងអាចរក្សាបានសន្តិភាព ស្ថិរភាព និងឯកភាពជាតិ ។

ទូលបង្គំខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់ជនរួមជាតិទាំងអស់ ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស កសិករ កម្មករ អាជីវករ សិស្ស និស្សិត បញ្ញវន្ត បុគ្គលិកនិយោជិត មន្ត្រីរាជការ កងទ័ព នគរបាល ខិតខំរក្សានិងពង្រឹងឆ្នងមហាសាមគ្គីជាតិ អោយកាន់តែរឹងមាំឡើងដើម្បីកសាង និងការពារមាតុភូមិយើង ។

ជាទីបញ្ចប់ ទូលបង្គំខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយនិងប្រគេនពរសម្តេចព្រះសង្ឃរាជទាំង២គណៈព្រះថេរានុថេរគ្រប់ព្រះអង្គជាទីសក្ការៈ និងសូមប្រសិទ្ធិពរបងប្អូនរួមជាតិទាំងនៅក្នុងប្រទេសនិងក្រៅប្រទេស សូមប្រកបនឹងពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរព្រះគុណ សូមអរគុណ !